ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៥៤ សហវ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និង ការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន

### ទេសរដ្ឋមន្ត្រី

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៣៣ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញប្រកាសរួមលេខ ៥៧៦ សហវ.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- បានឃើញប្រកាសរួមលេខ ៥៧៧ សហវ.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស្ដីពី ការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីការបង្ក្រាបបទល្មើសគ្រឿងញៀន
- បានឃើញលិខិតលេខ ១២៤២ កយ.រប/១៦ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងយុត្តិធម៌
- បានឃើញលិខិតលេខ ០១១/១៦ អ.ត.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញលិខិតលេខ ៧៦/២០១៦ ចបជ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ របស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស
- បានឃើញលិខិតលេខ ១៦៤ ស.ជ.ណ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ
- យោងតាមតម្រូវការចាំបាច់

## **<u>សម្រេច</u>**

**ប្រការ១.-**

បង្កើតគណៈកម្មការអន្តរក្រសួង ស្ថាប័នមួយ តទៅហៅថា "គណៈកម្មការ" ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | ឯកឧត្ដម **ឈន សុភាព** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | ឯកឧត្ដម នាយឧត្ដមសេនីយ៍ **មាស វីរិទ្ធ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | អនុប្រធាន |
| ៣. | ឯកឧត្ដម **នេត មុន្នី** អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៤. | ឯកឧត្ដម **ម៉ុក ម៉ាន់នី** អនុរដ្ឋលេខាធិការ នៃក្រសួងយុត្តិធម៌ | សមាជិក |
| ៥. | ឯកឧត្ដម ឧត្ដមសេនីយ៍ឯក **ម៉ក់ ជីតូ** អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៦. | ឧត្ដមសេនីយ៍ទោ **ម៉ន សាម៉ុន** មេបញ្ជាការរង នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |

**ប្រការ២.-**

គណៈកម្មការ មានភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួលការងារពាក់ព័ន្ធនឹងដំណើរការក្នុងការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិរឹបអូស
- ធ្វើការកត់ត្រាបញ្ជីសារពើភណ្ឌ ផ្ទៀងផ្ទាត់ និងបញ្ជាក់ពីភាពត្រឹមត្រូវលើទ្រព្យសម្បត្តិបានរឹបអូសដែលមានការពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- សហការជាមួយ ក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលបញ្ជីទ្រព្យសម្បត្តិ និងឯកសារពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- បញ្ជូនបញ្ជីទ្រព្យសម្បត្តិពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ទៅប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឬ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រគល់ជូន។

**ប្រការ៣.-**

**គណៈកម្មការ** ត្រូវដំណើរការកិច្ចប្រជុំជាប្រចាំតាមកាលកំណត់ តាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធាន។ ប្រធាន **គណៈកម្មការ** អាចប្រគល់សិទ្ធិជូនអនុប្រធានក្នុងការដឹកនាំកិច្ចប្រជុំក្នុងករណីប្រធានអវត្តមាន។

**ប្រការ៤.-**

ប្រធាន **គណៈកម្មការ** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំអគ្គនាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំព្រមទាំងមន្ត្រីបច្ចេកទេស នៃក្រសួង ស្ថាប័ន រាជធានី ខេត្ត ដែលពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ និងបំពេញការងារ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងសេចក្តីសម្រេចនេះ ។

**ប្រការ៥.-**

**គណៈកម្មការ** មានលេខាធិការដ្ឋានមួយ ជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួនដែលមានសមាសភាពដូចខាងក្រោម÷

១. ឯកឧត្តម **នេត មុន្នី** អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — ប្រធាន

២. លោក **ឆាត សុផល** អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ — អនុប្រធាន

៣. លោក **ជុន ថារឿត** ប្រធាននាយកដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន — អនុប្រធាន

៤. លោក **ពេញ ទិមុល** អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ នៃក្រសួងយុត្តិធម៌ សមាជិក

៥. លោក **សាន សុទ្ធី** អនុប្រធានមន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ សមាជិក

៦. វរសេនីយ៍ឯក **អ៊ុំ ដេម៉ូ** ស្នងការរង នៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៧. លោក **វណ្ណា សំណាង** អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៨. លោក **សុខ ធី** អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៩. លោក **ណុំ ស៊ីនិត** អនុប្រធានលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១០. លោក **ម៉ៅន ម៉ុនណិត** អនុប្រធានលេខាធិការដ្ឋាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១១. លោក **លី ផានតារា** ប្រធានផ្នែក នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

១២. លោក **ជាតិ សុខា** មន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៣. លោក **ផាន់ មករា** មន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៤. លោក **លីម លាងហេង** មន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

**ប្រការ៦.-**

លេខាធិការដ្ឋានមានភារៈកិច្ច ដូចខាងក្រោម÷

- ជាសេនាធិការឱ្យ គណៈកម្មការ ក្នុងការបំពេញការងាររបស់គណៈកម្មការ ដូចមានចែងក្នុងប្រការ ២ នៃសេចក្តីសម្រេចនេះ
- ចុះប្រមូលព័ត៌មានពាក់ព័ន្ធ ការតាមដាន ការប្រមូល ការគ្រប់គ្រង និង ការចាត់ចែងទ្រព្យសម្បត្តិ បានមកពីការរឹបអូសពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនតាមការចង្អុលបង្ហាញរបស់គណៈកម្មការ
- រៀបចំឯកសារវាយតម្លៃទ្រព្យសម្បត្តិបានមកពីការរឹបអូសពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន

- រៀបចំឯកសារ និងចាត់ចែង រៀបចំកិច្ចប្រជុំរបស់ **គណៈកម្មការ** ស្របតាមការណែនាំរបស់ប្រធាន **គណៈកម្មការ**
- រៀបចំកំណត់ហេតុប្រជុំ ដាក់ជូនប្រធាន **គណៈកម្មការ**
- ផ្តល់យោបល់ និងរៀបចំរបាយការណ៍ពាក់ព័ន្ធការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិបានមកពីការរឹបអូសពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនជូនប្រធាន **គណៈកម្មការ**
- ចូលរួមរៀបចំសិក្ខាសាលា សន្និសិទ្ធកាសែត ការបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗពាក់ព័ន្ធការតាមដាន ការប្រមូល ការគ្រប់គ្រង និង ការចាត់ចែងទ្រព្យសម្បត្តិបានមកពីការរឹបអូសពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន
- បំពេញការងារបន្ថែមទៀតតាមការកំណត់របស់ប្រធាន **គណៈកម្មការ** ។

**ប្រការ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក និង ប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង អគ្គលេខាធិការ និងប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងប្រធានអង្គភាពនានា នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ១ និងប្រការ៥ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

<u>**កន្លែងទទួល៖**</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ